វិទ្យាស្ថានបើកទូលាយ
Open Institute

# លទ្ធផលសង្ខេបវេទិកាពិភាក្សាលើកទី២
# ស្តីពី

# « ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងការទទួលព័ត៌មាន »

ឧបត្ថម្ភថវិកាដោយ ៖

OPEN SOCIETY INSTITUTE






# « ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងការទទួលព័ត៌មាន »

រៀបចំដោយ ៖  សម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ និង អង្គការវិទ្យាស្ថានបើកទូលាយ

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២

សមាជិកចូលរួមក្នុងវេទិកា៖ ២៨នាក់(ស្ត្រី១៧នាក់ និង បុរស១១នាក់)

- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ( ៩រូប )
- តំណាងស្ថាប័នរាជរដ្ឋាភិបាល ( ៣រូប)
- តំណាងអង្គការមិនមែនរដ្ឋាភិបាល (១៦រូប )

# គោលបំណងនៃវេទិកាពិភាក្សា

- ផ្តល់ឱកាសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីចែករំលែកនូវបទពិសោធន៍ និងឧបសគ្គនានាអំពីការទទួលព័ត៌មានទាក់ទងនឹងការងាររបស់គាត់។

- កំណត់យុទ្ធសាស្ត្រនានាដើម្បីជំរុញការទទួលព័ត៌មានឲ្យបានកាន់តែប្រសើរសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី។

# សំណួរពិភាក្សា

១.តើក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងក្រុមប្រឹក្សាឃុំសង្កាត់ជាបុរសទទួលបានព័ត៌មានស្មើភាពគ្នាដែរឬទេ? ហេតុអ្វី?

២.តើក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីទទួលបានព័ត៌មានពីណា?

៣.តើព័ត៌មានប្រភេទណាខ្លះដែលក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីទទួលបាននិងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់?និងដោយរបៀបណា?

៤.តើមានឧបសគ្គអ្វីខ្លះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីក្នុងការចូលទៅកាន់ព័ត៌មាន?

៥.តើមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីជំរុញក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីទទួលព័ត៌មានកាន់តែច្រើន?

៦.តើយើងត្រូវការគោលនយោបាយ ឬច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែរឬទេ?

# លទ្ធផលពិភាក្សា

## ១.តើក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងក្រុមប្រឹក្សាឃុំសង្កាត់ជាបុរសទទួលបានព័ត៌មានស្មើភាពគ្នាដែរឬទេ? ហេតុអ្វី?

លទ្ធផលពិភាក្សាឆ្លុះបញ្ចាំងបង្ហាញឲ្យឃើញថា ជា ទិដ្ឋភាពទូទៅ បើ ស្ត្រីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ស្ត្រីទទួលបានព័ត៌មានទូលាយជាងបុរស។ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទទួលបានព័ត៌មានអំពីស្ត្រីច្រើនជាងបុរស តាមរយៈ ការងាររបស់គាត់ចុះទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ប្រជុំក្រុមប្រឹក្សាមួយខែម្តង និង ការចុះតាមភូមិ។ ប៉ុន្តែការទទួលព័ត៌មានរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីនៅមានកម្រិតបើប្រៀបធៀបជាមួយក្រុមប្រឹក្សាឃុំសង្កាត់ជាបុរសជាពិសេសនៅតាមជនបទ តំបន់ដាច់ស្រយាល។

# លទ្ធផលពិភាក្សា

## ២. តើក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីទទួលបានព័ត៌មានពីណា?



# លទ្ធផលពិភាក្សា

## ៣.តើព័ត៌មានប្រភេទណាខ្លះដែលក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីទទួលបាននិងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់?

- ព័ត៌មានទាក់ទងនឹងសុខភាព
- ព័ត៌មានអំពីចំណាកស្រុក
- អំពើហិង្សាក្នុងគ្រួសារ
- ការបន្តពូជ ការពន្យារកំណើត
- ការបោះឆ្នោត
- គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

# លទ្ធផលពិភាក្សា

## ៤.តើមានឧបសគ្គអ្វីខ្លះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីក្នុងការចូលទៅកាន់ព័ត៌មាន?

- ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីដែលទើបតែជាប់ឆ្នោតថ្មី មិនសូវបានយល់ដឹងពី សិទ្ធិ អំណាច និងតួនាទី
- កង្វះខាតចំណេះដឹងផ្នែកកត់ត្រា ចងក្រងព័ត៌មាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា ប្រព័ន្ធអ៊ីនធឺណិត
- មានបន្ទុកគ្រួសារ
- វ័យ និង សុខភាព
- ខ្វះភាពក្លាហាន បញ្ចេញមតិយោបល់
- ផ្ទត់គំនិតចាស់
- សុវត្ថិភាព(ការធ្វើដំណើរទៅទីឆ្ងាយចូលរួមចូលរួមប្រជុំទទួលព័ត៌មាន)

# លទ្ធផលពិភាក្សា

## ៥.តើមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីជំរុញក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីទទួលព័ត៌មានកាន់តែច្រើន?

- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី ជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់ដែលទើបតែជាប់ឆ្នោតអាណត្តិថ្មីអំពីរបៀបការកត់ត្រា ការសរសេររបាយការណ៍ ការទុកឯកសារ ភាពជាអ្នកដឹកនាំ  និងជំនាញផ្នែកបច្ចេកវិទ្យាការប្រើប្រាស់កុំព្យូទ័រ ការប្រើប្រាស់អ៊ីនធឺណិតក្នុងការស្វែងរកព័ត៌មាន
- គាំទ្រថវិកាបន្ថែមដល់ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី។
- គួរផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសេវាផ្សព្វផ្សាយសាធារណៈឲ្យបានច្រើនជាងដើម្បីជួយទ្រទ្រង់ជីវិតឲ្យមានភាពប្រសើរជាង ។
- ជំរុញ បង្កើតឱកាស និងលើកទឹកចិត្តស្ត្រីចូលរួម ធ្វើសេចក្តីសម្រេចក្នុងកិច្ចការការងារធំសំខាន់ៗឲ្យបានច្រើន ដោយផ្លាស់ប្តូរផ្នត់គំនិតថាការងារកំប៉ិកកំប៉ុកជារបស់ស្ត្រី។

# ៦.តើយើងត្រូវការគោលនយោបាយ ឬច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែរឬទេ?



បើមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ជាការប្រសើរ ពីព្រោះវាឆ្លុះបញ្ចាំងពីតម្លាភាព លុបបំបាត់អំពើពុករលួយ លើកកម្ពស់គុណនេយ្យភាព អភិបាលកិច្ចល្អ និង លទ្ធិប្រជាធិបតេយ្យ។

សូមអរគុណ!